## វិធីការពារភ្លើងឆេះនៅពេលបុណ្យ (Holiday Fire Prevention)

WUML, 12/11/05

រដូវនេះ ជារដូវបុណ្យគ្រិស្មាស៍ ហើយជាពេលដែលប្រជាជនជាច្រើនបាននាំគ្នាតែងដើមគ្រិស្មះទ្រី និងតែងភ្លើងអំពូលដើម្បីរៀបចំអបអរសាទរបុណ្យចូលឆ្នាំថ្មី។ ជាមួយគ្នានេះ ក៏ជារដូវដែល សំបូរណ៍ទៅដោយភ្លើងឆេះផ្ទះដែលបណ្តាលមកពីគ្រោះថ្នាក់ផ្សេងៗពីការតែងនេះបានដែរ។

ខាងក្រោមនេះ ជាយោបល់ខ្លះៗ ពីក្រសួងការពារភ្លើងឆេះនៃរដ្ឋម៉ាស្សាឈូសេត ស្តីអំពីវិធីការពានិងប្រុងប្រយ័ត្នកុំឲ្យភ្លើងឆេះផ្ទះបាន៖

**ពេលតែងដើមឈើ៖**

- សូមកុំប្រើទៀនដុតជិតដើមឈើ
- ដាក់ដើមឈើឲ្យឆ្ងាយពី កំដៅហ៊ីត
- កុំប្រើដើមឈើស្រស់ដាក់តាំងនៅតាមកន្លែងសាធារណៈ ដូចជាហាលសាធារណៈ ភោជនិយដ្ឋានជាដើម
- ចាក់ទឹកដើមឈើឲ្យបានរាល់ថ្ងៃ
- ប្រើប្រដាប់ដោតដើមឈើ ដែលជាប់ពុំដួល
- ប្រើប្រដាប់តែងដើមឈើដែលពុំឆេះភ្លើង
- កុំដាក់តាំងដើមឈើនៅកន្លែងស្ងាត់ ដែលយើងពុំមានពេលមើលរក្សាឲ្យបានជិតដល់
- ចោលដើមឈើបន្ទាប់ពីថ្ងៃបុណ្យ ដើម្បីកុំឲ្យស្លឹកស្ងួតទាន់
- បើប្រើដើមឈើជ័រ សូមមើលផ្លាក់ដែលដាក់ថា ពុំអាចឆេះភ្លើងបាន។

**ចំពោះអំពូលភ្លើងវិញ៖**

- សូមដកភ្លើងចេញមុនពេលចូលទទួទានដំណេក
- ពន្លត់ទៀននៅពេលចេញពីបន្ទប់ សូមកុំទុកភ្លើងទៀនចោលដោយគ្មានអ្នកនៅទីនោះ
- ទិញអំពូលភ្លើងដែលមានដាក់ អក្សរ (UL) Underwriters Laboratory.
- ពិនិត្យមើលភ្លើងកុំឲ្យមានអំពូលបែក, ខ្សែរភ្លើងរបក, ឬកន្លែងដោតភ្លើងខូចខាត។
- កុំដោតភ្លើងនៅកន្លែងដោតតែមួយច្រើនពេក ដោយប្រើប្រដាប់ដោតតែបី សំរាប់ខ្សែតនីមួយៗ
- សូមកុំដុតទៀននៅជិតដើមឈើស្រស់ ឬប្រដាប់តែងដែលឆេះ
- បើសិនជាតែងអំពូលភ្លើងនៅក្រៅផ្ទះ សូមប្រើអំពូលដែលសំរាប់តែងនៅក្រៅផ្ទះ។

អត្ថបទនេះដកស្រង់ជាចំណែកពីពត៌មាន Winter Holiday Five Safety នៃក្រសួងកាពារភ្លើងឆេះនៃរដ្ឋម៉ាស្សាឈូសេត (Massachusetts Department of Fire Services), អស័យដ្ឋាន www.mass.gov/dfs, និងបកប្រែដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។